**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី**
លេខ...១៧៨៧...កកន

**សូមគោរពជូន**
**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**
**និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ប.ជ**

**កម្មវត្ថុ៖** សំណើសុំអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចំនួន **០៣រូប** ចូលរួមកិច្ចប្រជុំរបស់ក្រុមការងារអន្តរក្រសួង ដើម្បីបន្តពិនិត្យនិងឆ្លងសេចក្តីព្រាងច្បាប់ស្តីពី ការពពោះជំនួស ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **លោកជំទាវ** មេត្តាជ្រាបថា៖ ក្រសួងកិច្ចការនារី នឹងរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងដើម្បី **បន្តពិនិត្យ និងឆ្លងសេចក្តីព្រាងច្បាប់នេះ** ។ កិច្ចប្រជុំនឹងប្រព្រឹត្តទៅក្រោមអធិបតីភាព **លោកជំទាវរដ្ឋមន្ត្រី** ក្រសួងកិច្ចការនារី តាមកាលបរិច្ឆេទ និងទីកន្លែងដូចខាងក្រោម ៖

- **កាលបរិច្ឆេទ** ៖ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៧
- **ទីកន្លែង** ៖ ទីស្តីការក្រសួងកិច្ចការនារី ( ជាន់ទី ៣ )
- **វេលាម៉ោង** ៖ ៨ និង ៣០នាទីព្រឹក
- **ទូរស័ព្ទទំនាក់ទំនង** ៖ ០១២ ២២២ ៩៩៧ / ០៩៥ ៨៨៨ ៦៨៧ ឬ Email: bunputhy@yahoo.com

បញ្ជាក់៖ សូមយកមកជាមួយនូវ ឯកសារសេចក្តីព្រាងច្បាប់ស្តីពី ការពពោះជំនួស ( បានចែកជូនក្នុងកិច្ចប្រជុំថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៧ )។

អាស្រ័យហេតុនេះ សូម **លោកជំទាវ** មេត្តាអនុញ្ញាតជូនថ្នាក់ដឹកនាំនិងមន្ត្រីជំនាញចំនួន០៣ រូប ដូចមានរាយនាមខាងក្រោម៖

១.លោកជំទាវ **រ៉ន សិរីលក្ខណា** អគ្គលេខាធិការរង និងជាសមាជិកា នៃក្រុមការងារអន្តរក្រសួង
២.ឯកឧត្តម **សួរ ឌីម៉ា** អនុប្រធានក្រុមប្រឹក្សានីតិកម្ម និងជាសមាជិកក្រុមការងារ
៣.លោកឧត្តមសេនីយ៍ត្រី **កែប សារឿន** ប្រធាននាយកដ្ឋានកិច្ចការយុត្តិធម៌ និងជាសមាជិកក្រុមការងារ អញ្ជើញចូលរួមតាមសំណើសុំខាងលើ ដោយក្តីអនុគ្រោះ ។

សូម **លោកជំទាវ** ទទួលនូវការគោរពរាប់អានពីខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**
**សាន្ត-អរុណ**

ឯកភាព
12/10/17

**ចម្លងជូន៖**
- សាម៉ីខ្លួន
- ឯកសារ -កាលប្បវត្តិ

ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩
ទូរសារ : ០២៣ ៨៨០ ៧៣៧

# របៀបវារៈ
## កិច្ចប្រជុំក្រុមការងារអន្តរក្រសួង
## ដើម្បីបន្តពិនិត្យ ឆ្លងសេចក្ដីព្រាងច្បាប់ ស្ដីពីការពពោះជំនួស

ទីស្ដីការក្រសួងកិច្ចការនារី, ថ្ងៃទី១៩ ខែ តុលា ឆ្នាំ២០១៧ វេលាម៉ោង ៨ : ៣០ នាទីព្រឹក

| **ពេលវេលា** | **សកម្មភាព** | **អ្នកទទួលខុសត្រូវ** |
|---|---|---|
| ម៉ោង០៨:១៥<br>ដល់ ម៉ោង០៨:៣០ | ជួបជុំ សមាជិក សមាជិកាកិច្ចប្រជុំ | ក្រុមការងារ |
| ម៉ោង០៨:៣០<br>ដល់ ម៉ោង០៨:៤៥ | មតិស្វាគមន៍ និងប្រកាសបើកកិច្ចប្រជុំ | **លោកជំទាវ រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី** |
| ម៉ោង០៨:៤៥<br>ដល់ម៉ោង១០:០០ | បទបង្ហាញសេចក្ដីព្រាងច្បាប់ ស្ដីពីការពពោះជំនួស (ជំពូក២ និង ជំពូក បន្តបន្ទាប់)<br>មតិចូលរួម លើសេចក្ដីព្រាងច្បាប់ | **ល.ឌ សាខឿន សាវ៉ាតឌី<br>ឯ.ឧទីប្រឹក្សាផ្នែកច្បាប់<br>សមាជិកអន្តប្រជុំ** |
| ម៉ោង១០:០០<br>ដល់ម៉ោង១០:១០ | សម្រាក ពិសាអាហារសម្រន់ | ក្រុមការងារ |
| ម៉ោង១០:១០<br>ដល់ម៉ោង១១:១៥ | បទបង្ហាញ បន្ត និង ការពិភាក្សា | |
| ម៉ោង១១:១៥<br>ដល់ម៉ោង១១:៣០ | មតិបូកសរុប និង បិទកិច្ចប្រជុំ | **លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី** |

របៀបវារៈខាងលើរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី**
**ក្រុមការងារបច្ចេកទេស នៃក្រុមការងារអន្តរក្រសួង**
**រៀបចំច្បាប់ស្តីពីការពពោះជំនួស**

## របាយការណ៍
## ស្តីពីលទ្ធផល នៃកិច្ចប្រជុំក្រុមការងារអន្តរក្រសួង
## ឆ្លងសេចក្តីព្រាងច្បាប់ ស្តីពីការពពោះជំនួស

កាលពីរសៀលថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៧ ក្រុមការងារអន្តរក្រសួង ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស បានរៀបចំកិច្ចប្រជុំ ពិនិត្យ ឆ្លងសេចក្តីព្រាងច្បាប់នេះ ។ កិច្ចប្រជុំ បានប្រព្រឹត្តទៅនៅទីស្តីការក្រសួងកិច្ចការនារី ក្រោមអធិបតីភាព **លោកជំទាវរដ្ឋមន្ត្រី** ក្រសួងកិច្ចការនារី និង ជាប្រធានក្រុមការងារ ។

វត្តមានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ រួមមានៈ ឯកឧត្តម ជីវ សុងហាក់ អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម ពេជ អង្គ មេធាវី និងជាទីប្រឹក្សាផ្នែកច្បាប់ លោកជំទាវ ឯកឧត្តម លោកស្រី លោក ជាអនុប្រធាន និងជាសមាជិកក្រុមការងារអន្តរក្រសួង សរុបចំនួន ២៣ នាក់ ក្នុងនោះស្រី ១៥នាក់ ។

បន្ទាប់ពី **លោកជំទាវរដ្ឋមន្ត្រី** ក្រសួងកិច្ចការនារី និង ជាប្រធានក្រុមការងារ មានប្រសាសន៍បើកកិច្ចប្រជុំរួចមក ក្រុមការងារបច្ចេកទេសនៃក្រុមការងារបានធ្វើបទបង្ហាញនូវសេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស ជំពូក ១ មាន ៤មាត្រា និងដាក់ជូនសមាជិក សមាជិកាអង្គប្រជុំ ចូលរួម ពិនិត្យ ពិភាក្សា កែសម្រួល និងបំពេញបន្ថែម ក្នុងមាត្រានីមួយៗជាបន្តបន្ទាប់ ។ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងស្និតស្នាញ មួយមាត្រាម្តងៗ បានចំនួន៤ មាត្រា ជាលទ្ធផលមានដូចខាងក្រោមៈ

មាត្រា១.បានកែសម្រួលឡើងវិញមានខ្លឹមសារដូចតទៅៈ " *ច្បាប់នេះមានគោលបំណងគ្រប់គ្រងការពពោះជំនួស ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហព័ទ្ធដែលភរិយាគ្មានលទ្ធភាពពពោះ ហើយស្វែងរកការពពោះជំនួសប្រកបដោយសីលធម៌ និងទប់ស្កាត់ការយកកម្រៃ ឬធ្វើអាជីវកម្មលើការពពោះជំនួសរបស់ស្ត្រី ព្រមទាំងបង្ការការប្រើប្រាស់ដោយបំពាន នូវបច្ចេកវិទ្យាជំនួយការបង្កកំណើត និងធានានូវឧត្តមប្រយោជន៍របស់កុមារដែលកើតពីការពពោះជំនួស ។*"

មាត្រា២.-បានកែសម្រួលឡើងវិញមានខ្លឹមសារដូចតទៅៈ " *ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងការពពោះជំនួស រួមទាំងការបរិច្ចាគនិងប្រើប្រាស់មេជីវិត ស្របតាមគោលការណ៍ស្ម័គ្រចិត្ត មនុស្សធម៌ និងសប្បុរសធម៌ ព្រមទាំងបញ្ជាក់ពីភាពជាឪពុកម្តាយ និងកាតព្វកិច្ចរបស់ឪពុកម្តាយ អ្នកបរិច្ចាគ និងអ្នកពពោះជំនួស ។*"

មាត្រា៣.- ចំពោះខ្លឹមសារក្នុង មាត្រា៣ បន្ទាប់ពីសមាជិក សមាជិកាអង្គប្រជុំ បានជជែក ពិភាក្សា មិនទាន់បានឯកភាពសម្រេច គឺអង្គប្រជុំស្នើសុំទុកពិនិត្យឡើងវិញ និង កែពេលក្រោយ ។

មាត្រា៤.-និយមន័យ វាក្យស័ព្ទបច្ចេកទេសសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ អង្គប្រជុំបានឯកភាពសម្រេចដូចខាងក្រោម៖

១.ចំណុចទី១ និងចំណុចទី២ បានឯកភាពដកចេញ

២.ចំណុចទី៣ លុបពាក្យទារកក្នុងស្បូន ជំនួសដោយពាក្យ " សំណុំកោសិកាកំណាជីវិត "

៣. ចំណុចទី៤ បានឯកភាព " *ការពពោះជំនួសសំដៅដល់ការពពោះដែលបង្កកំណើត តាមវិធីសិប្បនិម្មិត ឬ ដោយមានជំនួយពីសេវាវេជ្ជសាស្ត្រដល់ការបន្តពូជ ដោយមិនមានការរួមភេទ* " ។

៤. ចំណុច ទី៥ ទី៦ និងទី៧ ដោយចំណុចទាំងនេះ ពាក់ពន្ធ័ទៅនឹងបច្ចេកទេសសុខាភិបាល អង្គប្រជុំបានស្នើសុំឱ្យតំណាងក្រសួងសុខាភិបាល ពិនិត្យ កែសម្រួលជាមុនសិន

៧.ចំពោះបណ្តាចំណុចមួយចំនួនទៀតដែលនៅសល់ក្នុងមាត្រា៤នេះ អង្គប្រជុំបានឯកភាព នឹងយកទៅពិចារណាបន្ថែមទៀត ឱ្យបានសមស្របតាមខ្លឹមសារនៃមាត្រាដែលពាក់ព័ន្ធ ទៅនឹងច្បាប់នេះ ។ ដោយឡែកចំណុចទី១១ ស្នើសុំយកទៅដាក់នៅខាងលើ ។

មុននឹងបញ្ចប់កម្មវិធី **លោកជំទាវរដ្ឋមន្ត្រី** ប្រធានអង្គប្រជុំ បានបូកសរុបលទ្ធផលកិច្ចប្រជុំ និងថ្លែងអំណរគុណចំពោះសមាជិកសមាជិកាទាំងអស់ ដែលបានយកចិត្តទុកដាក់ចូលរួម និងបានចូលរួមមតិយ៉ាងផុលផុស ។ អង្គប្រជុំ បានឯកភាពកំណត់យកព្រឹក ថ្ងៃទី១៩ ខែ តុលា ឆ្នាំ២០១៧ សម្រាប់ការប្រជុំលើកក្រោយ ព្រមទាំងសំណូមពរសុំសមាជិក សមាជិកាអង្គប្រជុំ មេត្តាពិនិត្យឯកសារមុន រួចអាចផ្ញើមកមន្ត្រីក្រុមការងារបច្ចេកទេស (ក្រសួងកិច្ចការនារី) តាមរយៈសារអេឡិចត្រូនិក មានអ៊ីមែល bunputhy@yahoo.com ឬ តេឡេក្រាម ឬ WhatsApp ដែលមានលេខទំនាក់ទំនង ០៩៥ ៨៨៨ ៦៨៧ យ៉ាងយឺតត្រឹមថ្ងៃសុក្រទី ១៣ ខែតុលា ឆ្នាំ២០១៧ ដើម្បីក្រុមការងារបូកសរុប ដាក់ជូនអង្គប្រជុំនាថ្ងៃទី១៩ ខែ តុលា ឆ្នាំ២០១៧ ។

អង្គប្រជុំបានដំណើរការចប់សព្វគ្រប់ នៅវេលាម៉ោង ១៨គត់ ក្រោមបរិយាកាសយកចិត្តទុកដាក់ និងទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១៧

**អ្នកធ្វើរបាយការណ៍**

[signature]

**ប៊ុន ពុទ្ធី**

បានឃើញ និង ឯកភាព

**រដ្ឋលេខាធិការ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារ**

[signature]

**សាន្ត-អរុណា**